# ប្រជាមតិស្តីពីសំឡេងជនជាតិដើម និងអ្នកដីកោះ Torres Strait

ប្រជាជនអូស្ត្រាលីមកពីទឹកដីជាច្រើន អនុវត្តជំនឿជាច្រើន និងនិយាយភាសាជាច្រើនផងដែរ។ ជនជាតិដើម និងអ្នកដីកោះ Torres Strait គឺជាប្រជាជនដំបូងគេនៃប្រទេសអូស្ត្រាលី ហើយបានរស់នៅទីនេះជាង 65,000 ឆ្នាំមកហើយ។ក៏ប៉ុន្តែ រដ្ឋធម្មនុញ្ញរបស់ប្រទេសអូស្ត្រាលីមិនទទួលស្គាល់ឋានៈពិសេសរបស់ពួកគេទេ។ ហេតុដូច្នេះហើយនៅចុងឆ្នាំនេះ យើងនឹងអាចពិចារណាដើម្បីកែប្រែរដ្ឋធម្មនុញ្ញរបស់យើងតាមរយៈការធ្វើប្រជាមតិ។
ប្រជាជនអូស្ត្រាលីទាំងអស់នឹងមានឱកាសទទួលស្គាល់សិទ្ធិនានារបស់ ជនជាតិដើម និងអ្នកដីកោះ Torres Strait នៅក្នុងរដ្ឋធម្មនុញ្ញរបស់យើងតាមរយៈ សំឡេងមួយដែលនឹងធានាថាពួកគេត្រូវបានគេស្តាប់ឮ អំពីបញ្ហានានាដែលប៉ះពាល់ដល់ពួកគេ។។

## តើអ្វីទៅសេចក្តីថ្លែងការណ៍ Uluru ចេញពីបេះដូង (Uluru Statement from the Heart)?

នៅខែឧសភា ឆ្នាំ2017 ប្រជាជនជាតិដើម និងអ្នកដីកោះ Torres Strait ជាង 250 នាក់បានចេញសេចក្តីថ្លែងការណ៍ Uluru ចេញពីបេះដូង (Uluru Statement from the Heart)។ វាស្នើសុំឱ្យយើងបង្កើតអនាគតដ៏ល្អប្រសើរមួយសម្រាប់ប្រទេសអូស្ត្រាលីទាំងមូល ហើយដាក់បញ្ចូលសំឡេងជនជាតិដើម និងអ្នកដីកោះ Torres Strait នៅក្នុងរដ្ឋធម្មនុញ្ញអូស្ត្រាលី។

## តើអ្វីទៅសំឡេងជនជាតិដើម និងអ្នកដីកោះ Torres Strait?

សំឡេងជនជាតិដើម និងអ្នកដីកោះ Torres Strait គឺជាមធ្យោបាយមួយសម្រាប់ ប្រជាជនជាតិដើម និងអ្នកដីកោះ Torres Strait ដើម្បីណែនាំរដ្ឋាភិបាលអំពីច្បាប់ និងគោលនយោបាយនានាដែលប៉ះពាល់ដល់ពួកគេ។

## តើប្រជាមតិជាអ្វី?

ប្រជាមតិគឺជាពេលណាអ្នកបោះឆ្នោតត្រូវបានស្នើសុំឱ្យឆ្លើយ បាទ/ចាស ឬទេ ទៅនឹងសំណួរមួយ ឬសំណួរនានា។មធ្យោបាយតែមួយគត់ដើម្បីកែប្រែរដ្ឋធម្មនុញ្ញរបស់ប្រទេសអូស្ត្រាលីគឺតាមរយៈការធ្វើប្រជាមតិ។

## តើនរណាអាចបោះឆ្នោតប្រជាមតិ?

មានតែប្រជាជនដែលបានចុះឈ្មោះបោះឆ្នោតប៉ុណ្ណោះ អាចចូលរួមក្នុងការធ្វើប្រជាមតិ។ការបោះឆ្នោតប្រជាមតិគឺជាកាតព្វកិច្ច សម្រាប់អ្នកបោះឆ្នោតដែលបានចុះឈ្មោះ។

## តើខ្ញុំបោះឆ្នោតប្រជាមតិដោយរបៀបណា?

ការធ្វើប្រជាមតិគឺដូចគ្នានឹងការបោះឆ្នោតជ្រើសតាំងដែរ។នៅថ្ងៃបោះឆ្នោត អ្នកអាចទៅកន្លែងបោះឆ្នោតមួយ ហើយបោះឆ្នោតរបស់អ្នកនៅលើសន្លឹកឆ្នោតមួយ។

## តើការធ្វើប្រជាមតិត្រូវបានគេសម្រេចដោយរបៀបណា?

ដើម្បីឱ្យប្រជាមតិទទួលបានជោគជ័យ វាត្រូវការសំឡេងភាគច្រើនពីរកម្រិត។នេះមានន័យថា សំឡេងសន្លឹកឆ្នោតភាគច្រើនយ៉ាងហោចណាស់បួនរដ្ឋ និងនៅទូទាំងប្រទេសអូស្ត្រាលីទាំងមូល។



អនុញ្ញាតដោយ Tabatha Feher, Life Without Barriers, L6, 107 Pitt St, Sydney, NSW.

## តើការធ្វើប្រជាមតិសំឡេងជនជាតិដើម និងអ្នកដីកោះ Torres Strait នឹងធ្វើឡើងនៅពេលណា ?

ការធ្វើប្រជាមតិសំឡេងជនជាតិដើម និងអ្នកដីកោះ Torres Strait នឹងធ្វើឡើងនៅចុងឆ្នាំនេះ។

## តើការធ្វើប្រជាមតិសំឡេងជនជាតិដើម និងអ្នកដីកោះ Torres Strait នឹងសួរសំណួរអ្វីខ្លះ ?

"ច្បាប់ដែលបានស្នើឡើង៖ ដើម្បីកែប្រែរដ្ឋធម្មនុញ្ញក្នុងការទទួលស្គាល់ប្រជាជនដំបូងនៃប្រទេសអូស្ត្រាលី ដោយការបង្កើតសំឡេងជនជាតិដើម និងអ្នកដីកោះ Torres Strait។ អ្នកយល់ព្រមលើការកែប្រែដែលបានស្នើឡើងនេះទេ ?

## តើនរណាបង្កើតសន្លឹកព័ត៌មាននេះ ?

សន្លឹកព័ត៌មាននេះបានបង្កើតឡើងដោយកិច្ចខិតខំប្រឹងប្រែងរួម របស់ Life Without Barriers, Reconciliation Australia, SNAICC – National Voice for our children, the Yes Alliance និង Polaron Language Services ពជាដៃគូនេះត្រូវបានបង្កើតឡើងដើម្បីជួយបង្កើតព័ត៌មានដែលអាចចូលដំណើរការបានស្តីពីសំឡេងជនជាតិដើម និងអ្នកដីកោះ Torres Strait។

**ព័ត៌មានបន្ថែម**

www.lwb.org.au



អនុញ្ញាតដោយ Tabatha Feher, Life Without Barriers, L6, 107 Pitt St, Sydney, NSW